# ១. សេចក្តីផ្តើម

សៀវភៅនេះជាចំណែកមួយនៃគម្រោងមួយអនុវត្តកាលពីខែមេសាឆ្នាំ ២០០២។ ជំហានដំបូងនៃគម្រោងនេះសំដៅរៀបចំសិក្ខាសាលាតំបន់មួយស្តីពីសកលកម្មនៃសិទ្ធិទទួលការអប់រំដែលមានគុណភាពល្អនៅទីក្រុងម៉ានីឡា ពីថ្ងៃ ២៩ ដល់ថ្ងៃ ៣១ ខែតុលា ឆ្នាំ ២០០២។ ការត្រៀមលក្ខណៈដើម្បីរៀបចំសិក្ខាសាលានេះរួមមានការងារជាច្រើន ដូចជា ចងក្រងឯកសារ វិភាគ និងសង្ខេបឯកសារ និងវិភាគរបាយការណ៍របស់រដ្ឋាភិបាលក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សសកលលោកទាក់ទងនឹងការអប់រំ។ ភាពស្រដៀងគ្នា និងភាពខុសគ្នាក្នុងការអនុវត្តនិយាមសិទ្ធិមនុស្សជាសកលនៅក្នុងយុទ្ធសាស្ត្រអប់រំជាតិ និងក្នុងការអនុវត្តន៍របស់ប្រទេសនីមួយៗជាការបន្ថែមបន្ទុកការងារដល់ការរៀបចំសិក្ខាសាលានោះផងដែរ។ ការវិភាគឯកសារនេះមានវិសាលភាពគ្របដណ្តប់លើប្រទេសដែលមានកំណត់តាមសមាជិកដែលបានចូលរួមក្នុងសិក្ខាសាលា ដូចជា កម្ពុជា ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន ថៃ និង វៀតណាម។ ខ្លឹមសារអត្ថបទក្នុងឯសារនេះក៏គ្របដណ្តប់ប្រទេសមួយចំនួននៅអាស៊ីផងដែរ ជាពិសេស លើកយកបទពិសោធន៍ពីប្រទេសក្នុងតំបន់ និងបង្ហាញអំពីបញ្ហាទូទៅលើសកលលោក។

ចាប់ពីដើមសហស្សវត្សរ៍ថ្មី យុទ្ធសាស្ត្រសកលលោកដើម្បីបង្កើតវិធីដោះស្រាយបញ្ហាឈរលើសិទ្ធិមនុស្សជាបង្អែកដើម្បីសំរេចការអប់រំបានឈានទៅរកចំណុចរួមសំរាប់ទាំងអស់គ្នា ហើយដោយសារយុទ្ធសាស្ត្រទាំងនេះទើបបង្កើតបាននូវឯកសារមួយនេះជាមូលដ្ឋាន។ នៅក្នុងប្រព័ន្ធអង្គការសហប្រជាជាតិ ការបញ្ជ្រាបសិទ្ធិមនុស្សនៅក្នុងកម្មវិធី និងគម្រោងជាការងារអាទិភាពយ៉ាងចំបង។ របាយការណ៍សកលលោកតាមដានការអប់រំសំរាប់ទាំងអស់គ្នា ២០០៣/០៤[1] ជាឧទាហរណ៍ ក៏បានបញ្ជ្រាប្រធានបទសិទ្ធិមនុស្សផងដែរ ហើយក៏បានបញ្ចូលស្ថិតិស្តីពីសិទ្ធិមនុស្សផងដែរ ប៉ុន្តែមិនបានបញ្ចូលនៅក្នុងឯកសារនេះទេ។

ការបញ្ជ្រាបសិទ្ធិមនុស្សចាំបាច់ត្រូវបញ្ចូលខ្លឹមសារសិទ្ធិមនុស្សតាមរយៈគោលនយោបាយអប់រំ និងការអនុវត្តន៍គោលនយោបាយទាំងនោះនៅគ្រប់កំរិតទាំងអស់ចាប់ពីថ្នាក់សកលលោកដល់សហគមន៍គឺធ្វើយ៉ាងណាចាត់ទុក "សិទ្ធិមនុស្សជាបេះដូងនៃសកម្មភាពទាំងអស់។"[2] ការបញ្ជ្រាបសិទ្ធិមនុស្សចាំបាច់ត្រូវបង្កើតបណ្តាញ និងទំនាក់ទំនងរវាងវិស័យសិទ្ធិមនុស្សជាមួយការអប់រំ និងការអភិវឌ្ឍន៍ក្នុងទិសដៅរួមមួយឈានទៅសំរេចគោលដៅនៃការអប់រំសំរាប់ទាំងអស់គ្នា កាត់បន្ថយភាពក្រីក្រ និងសំរេចសមភាពយេនឌ័រ ហើយជាលទ្ធផលចុងក្រោយគឺការវិភាគមួយអំពីអ្វីដែលមានលក្ខណៈឆ្លងវិស័យ។ ការអប់រំសំរាប់ទាំងអស់គ្នាមិនមែនជាទីបញ្ចប់តែមួយគត់ទេ ប៉ុន្តែ ជាមធ្យោបាយមួយដើម្បីបំពេញកិច្ចសន្យារួមដែលបានឯកភាពគ្នាជាសកល។

សិទ្ធិមនុស្សមាននៅក្នុងគ្រប់ច្បាប់ ដូច្នេះការបញ្ជ្រាបសិទ្ធិមនុស្សទៅក្នុងច្បាប់ គោលនយោបាយត្រូវស្វែងយល់ និងអនុវត្តតាមច្បាប់សិទ្ធិមនុស្សជាសកល។ សន្ធិសញ្ញាមួយចំនួនមានមនុស្សស្គាល់ច្រើន ដូចជាអនុសញ្ញាស្តីពីសិទ្ធិកុមារ ចំណែកឯសន្ធិសញ្ញាមួយចំនួនទៀតមិនសូវមានគេស្គាល់ទេ គឺស្គាល់តែក្រុមអ្នកច្បាប់។ សៀវភៅនេះមានបំណងបង្ហាញអ្នកអានឲ្យស្គាល់ច្បាប់សិទ្ធិមនុស្សដែលមានសារៈសំខាន់សំរាប់យុទ្ធសាស្ត្រអប់រំ និងការអនុវត្តន៍យុទ្ធសាស្ត្រអប់រំដែលមន្ត្រី និងភ្នាក់ងារអប់រំ ឬភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិងាយយល់ ងាយប្រើ និងងាយ បកស្រាយ ពន្យល់។ ច្បាប់សិទ្ធិមនុស្សអន្តរជាតិរួមមានបណ្តុំសន្ធិសញ្ញាដែលកំណត់អំពីនិយាមអប្បបរមាសំរាប់ តាក់តែងច្បាប់ទាក់ទងនឹងការអប់រំទូទាំងសកលលោក។

---

[1] Gender and Education for All: The Leap to Equality. EFA Global Monitoring Report 2003/4, available at www.unesco.org/education/efa_report

[2] General Assembly - Road map towards the implementation of the United Nations Millennium Declaration: Report of the Secretary-General, U.N. Doc. A/56/326, para. 201

ច្បាប់ទាំងនេះបំពេញបន្ថែមជាមួយវិធីដោះស្រាយបញ្ហាសិទ្ធិមនុស្សគន្លឹះៗដែលបានរៀបរៀងឡើងស្របតាមការអនុវត្តន៍សន្ធិសញ្ញាសិទ្ធិមនុស្សសកលលោកនៅគ្រប់ប្រទេសទាំងអស់។ ច្បាប់សិទ្ធិមនុស្សសកលលោកមួយចំនួនត្រូវបានបញ្ចូលក្នុងយុទ្ធសាស្ត្រអប់រំសកលលោក ដូចជា យុទ្ធសាស្ត្រលុបបំបាត់ការរើសអើងយេនឌ័រ ប៉ុន្តែយុទ្ធសាស្ត្រផ្សេងទៀតមិនសូវផ្សព្វផ្សាយឲ្យទូលំទូលាយទេ។ ឧទាហរណ៍មួយ នៅក្នុងយុទ្ធសាស្ត្រអប់រំសកលលោកមានពន្យល់តិចតួចបំផុតអំពីសិទ្ធិរបស់គ្រូបង្រៀន ហើយការអប់រំអំពីសាសនាមិនមានបញ្ជាក់បន្តិចសោះនៅក្នុងយុទ្ធសាស្ត្រនោះ។ រាល់ច្បាប់សិទ្ធិមនុស្សជាសកលទាំងអស់ត្រូវបានបង្ហាញជូននៅក្នុងសៀវភៅនេះដើម្បីឲ្យអ្នក អានងាយស្វែងយល់ឲ្យបានទូលំទូលាយ។ លើសនេះទៀត ការទទួលស្គាល់ថា សិទ្ធិមនុស្សមិនកើតមាននៅក្នុងសុញ្ញាកាសចាំបាច់ត្រូវវាយតម្លៃអំពីទំនាក់ទំនងរវាងសិទ្ធិមនុស្ស និងការអប់រំជាមុនសិន។ ផលវិបាកមួយដែលអាចកើតឡើងដោយសារការឲ្យតម្លៃខ្ពស់ទៅលើការអប់រំ និងដោយសារការអប់រំជាមធ្យោបាយកាត់បន្ថយភាពក្រីក្រគឺជាតម្រូវការមួយដើម្បីវាយតម្លៃលទ្ធផលចុងក្រោយបានពីការរៀបចំ និងអនុវត្តកម្មវិធីអប់រំជាតិដែលអាចធានាឲ្យសិស្សានុសិស្ស និងនិស្សិតមានសមត្ថភាពរកការងារធ្វើបាន និងបង្កើតការងារបាន។ លើសនេះទៀត ទំនាក់ទំនងក្នុងសង្គមរបស់កុមារ ជាទូទៅកើតឡើងតាមរយៈប្រព័ន្ធអប់រំ ហើយតម្លៃ និងគុណធម៌ដែលប្រព័ន្ធអប់រំផ្តល់ឲ្យដល់កុមារសំរាប់អនាគតរឹតតែមានសារៈសំខាន់ និងមានប្រយោជន៍បំផុត។

និយាមអប្បបរមានៃសិទ្ធិមនុស្ស និងវិធីដោះស្រាយបញ្ហាសិទ្ធិមនុស្សត្រូវបានសាកល្បងនៅតាមប្រទេសនានាដើម្បីស្វែងយល់ឲ្យកាន់តែច្បាស់ថា តើនិយាមអប្បបរមានោះត្រូវបានបកប្រែឲ្យទៅជាការអនុវត្តន៍ជាក់ស្តែងនៅតាមតំបន់ និងតាមប្រទេសដោយរបៀបណា។ ដោយសារសិទ្ធិមនុស្សជាបញ្ហាសកលដូច្នេះ ការបកប្រែសិទ្ធិមនុស្សឲ្យទៅជាការអនុវត្តន៍ជាក់ស្តែងក៏ជាបញ្ហាសកលដែរ។ ការកើតមាននៃបណ្តុំសន្ធិសញ្ញាសិទ្ធិមនុស្ស ការទទួលស្គាល់សន្ធិសញ្ញាដោយប្រទេសភាគច្រើននៅលើសកលលោក និងការអនុវត្តន៍អនុសញ្ញាទាំងនោះនៅតាមប្រទេសនានាលើសកលលោកគឺជាប្រភពផ្តល់ចំណេះដឹងដ៏សំបូរបែបអំពីសិទ្ធិមនុស្ស។ សៀវភៅនេះលើកយកមកនិយាយលំអិតអំពីចំណេះដឹងទាំងនេះដើម្បីជួយសម្រួលដល់អ្នកអានក្នុងការស្វែងយល់អំពីបញ្ហាសិទ្ធិមនុស្ស និងរកដំណោះស្រាយបញ្ហាសិទ្ធិមនុស្សផងដែរ។

ភាពស្មុគ្រស្មាញនៃច្បាប់អន្តរជាតិគឺជាបញ្ហាក្នុងការស្វែងយល់សំរាប់មនុស្សភាគច្រើន។ សៀវភៅនេះក៏មានគោលបំណងកាត់បន្ថយ និងលុបបំបាត់ បើអាចធ្វើទៅបាននូវបញ្ហាលំបាកយល់នេះផងដែរតាមរយៈការរៀបរៀងសេចក្តីណែនាំលំអិតសំរាប់ការអប់រំនៅក្នុងសន្ធិសញ្ញាសកលលោកដែលពាក់ព័ន្ធ និងតាមរយៈការសរសេរសេចក្តីសង្ខេបអំពីការអនុវត្តន៍ជាក់ស្តែងនៅអាស៊ី និងប៉ាស៊ីហ្វិក និងបណ្តាប្រទេសផ្សេងៗលើសកលលោកផងដែរ។ ការប្តេជ្ញាថ្មីៗរបស់អង្គការសហប្រជាជាតិក្នុងការបញ្ជ្រាបសិទ្ធិមនុស្សនៅក្នុងរបាយការណ៍របស់ខ្លួន ហើយការផ្លាស់ប្តូរជំហររបស់អង្គការយូណេស្កូក្នុងការធានាតាមដានកម្មវិធីដោយឈរលើសិទ្ធិមនុស្សជាមូលដ្ឋានទើបធ្វើឲ្យវិធីដោះស្រាយបញ្ហានេះយកមកប្រើទាន់ពេលវេលា។

សៀវនេះដកស្រង់ និងពន្យល់អំពីច្បាប់សកលធំៗដែលទាក់ទងនឹងការអប់រំ។ ច្បាប់ទាំងនេះមាននៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សជាច្រើន។ សន្ធិសញ្ញានីមួយៗមានហត្ថលេខីផ្សេងៗគ្នា ហើយពន្យល់លំអិតអំពីវិធីធ្វើរបាយការណ៍ ដោយឡែកមួយទៀត។ វិធីធ្វើរបាយការណ៍នេះមិនបានពន្យល់លំអិតថាត្រូវរកព័ត៌មានសំខាន់ពាក់ព័ន្ធ រហ័ស និងងាយស្រួលទេ ដូច្នេះសៀវភៅនេះបំពេញនូវតម្រូវការចាំបាច់នេះ។ ស្ថានភាពត្រូវកែប្រែមួយចំនួនដោយសារថា លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានប្រកាសអំពីកំណែទម្រង់ដែលមានគោលបំណងបញ្ចូលទៅក្នុងរបាយការណ៍របស់ខ្លួននូវសន្ធិសញ្ញាសិទ្ធិមនុស្សទាំងអស់[៣]ល្អិតណាខ្លឹមសារទាំងអស់អាចយល់ព្រម និងអនុវត្តបានគ្រប់ៗគ្នា ហើយខ្លឹមសារទាំងនោះត្រូវតែងាយយល់សំរាប់គ្រប់គ្នា ហើយអាចមានឱកាសប្រើប្រាស់ផងដែរ។

---

3 General Assembly - Strengthening of the United Nations: an agenda for further change. Report of the Secretary-General, U.N. Doc. A/57/387, paras. 52-54

ការអប់រំទាក់ទងយ៉ាងជិតស្និទ្ធជាមួយសន្ធិសញ្ញាសិទ្ធិមនុស្សសកលលោក ហើយបញ្ហាអប់រំនឹងត្រូវដោះស្រាយដោយស្ថាប័នពាក់ព័ន្ធទាំងអស់ ហេតុដូច្នេះក្របខ័ណ្ឌសកម្មភាពសិទ្ធិមនុស្សរួមមួយនឹងជួយកំណត់រកបញ្ហារួម និងដំណោះស្រាយរួមក្នុងបញ្ហាសិទ្ធិមនុស្ស។ សៀវភៅនេះប្រមូលផ្ដុំច្បាប់នានាដែលដកស្រង់ចេញពីសន្ធិសញ្ញាពាក់ព័ន្ធជាច្រើន ហើយបង្ហាញច្បាស់អំពីចំណុចស្នូលរបស់ក្របខ័ណ្ឌសកម្មភាពសិទ្ធិមនុស្សសកលលោក។ សន្ធិសញ្ញាសិទ្ធិមនុស្សផ្សេងគ្នាដោះស្រាយបញ្ហាសិទ្ធិទទួលការអប់រំផ្សេងគ្នា ហើយប្រមូលផ្ដុំជាកម្រងឯកសារមួយដែលបង្ហាញអំពីច្បាប់សិទ្ធិមនុស្សសំខាន់ៗទាំងអស់។ ដូចបានកត់សំគាល់ខាងលើ កាតព្វកិច្ចរបស់រដ្ឋាភិបាលផ្នែកសិទ្ធិមនុស្សគឺត្រូវធានាឲ្យមានធានារូបវ័ន្តសំរាប់អប់រំ ឱកាសចូលរៀន គុណភាពអាចទទួលយកបាន និងអាចកែប្រែឲ្យស្របតាមតម្រូវការជាក់ស្ដែង។[4] បញ្ញត្តិរបស់សន្ធិសញ្ញានានាត្រូវបានប្រមូលផ្ដុំដើម្បីធ្វើជាឯកសារយោងសំរាប់បញ្ហាសិទ្ធិមនុស្សកំណត់នៅក្នុងសៀវភៅនេះ។

ការទទួលស្គាល់ថា ច្បាប់សិទ្ធិមនុស្សសកលលោក និងយុទ្ធសាស្ត្រអប់រំសកលលោកជួយបំពេញចន្លោះឲ្យគ្នាទៅវិញទៅមកមានបង្ហាញការណែនាំ តម្រង់ទិសនៅក្នុងសៀវភៅនេះ។ តាមការពិត ក្របខ័ណ្ឌសកម្មភាពក្រុងដាកាបានបញ្ជាក់ច្បាស់ថា ការអប់រំជាមូលដ្ឋានគ្រឹះនៃសិទ្ធិមនុស្ស ហើយក្របខ័ណ្ឌនេះគូសបញ្ជាក់ច្បាស់អំពីសារៈសំខាន់នៃសកម្មភាពរបស់រដ្ឋាភិបាលដែលអនុវត្តឈរលើសិទ្ធិមនុស្សជាបង្អែកក្នុងការអនុវត្តការអប់រំសំរាប់ទាំងអស់គ្នានៅតាមប្រទេស។ ក្របខ័ណ្ឌសកម្មភាពនេះក៏បានគូសបញ្ជាក់ឡើងវិញអំពីសិទ្ធិទទួលការអប់រំដោយសំអាងលើក្របខ័ណ្ឌសកម្មភាពច្បាប់អន្តរជាតិដែលមានស្រាប់កាលពី ៥ ទសវត្សរ៍មុន។ រាល់កិច្ចខិតខំប្រឹងប្រែងដើម្បីសំរេចការអប់រំសំរាប់ទាំងអស់គ្នាក៏បានបង្ហាញ និងឆ្លុះបញ្ចាំងអំពីសិទ្ធិកុមារ និងតម្រូវការក្នុងការលុបបំបាត់ការរើសអើងយេនឌ័រក្នុងវិស័យអប់រំ ដែលការលុបបំបាត់នេះនឹងជួយបំពេញកង្វះចន្លោះមួយចំនួនក្នុងការសំរេចជោគជ័យលើការអនុវត្តន៍អនុសញ្ញាស្ដីពីសិទ្ធិកុមារដែលជាអនុសញ្ញាដែលមានការទទួលស្គាល់ជាទូទៅ និងជាសកលបំផុតក្នុងប្រវត្តិសាស្ត្រ។

ការយកចិត្តទុកដាក់លើការអប់រំសំរាប់ទាំងអស់គ្នា គឺផ្ដោតជាសំខាន់ទៅលើសកលកម្មអប់រំ គុណភាពអប់រំ និងការអប់រំដោយឥតបង់ថ្លៃដែលសន្យានៅក្នុងសេចក្ដីថ្លែងការណ៍សកលលោកស្ដីពីការអប់រំសំរាប់ទាំងអស់គ្នា និង សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ។

ដើម្បីធានាផ្ដល់សិទ្ធិទទួលការអប់រំឲ្យក្លាយជាការពិត និងដើម្បីសំរេចការអប់រំសំរាប់ទាំងអស់គ្នា គឺជាការងារដែលត្រូវអនុវត្តបន្តរហូត ដែលការងារទាំងពីរនេះបំពេញចំណុចខ្វះខាតឲ្យគ្នាទៅវិញទៅមក។ ប៉ុន្តែទិន្នន័យបរិវស័យ និងគុណវិស័យដែលមានស្រាប់អំពីសកម្មភាពការងារទាំងពីរនេះនៅតាមប្រទេសនីមួយៗតែងខុសគ្នា ដោយអាស្រ័យលើវិធីសាស្ត្រដែលប្រទេសនីមួយៗយកមកអនុវត្ត។ ឧទាហរណ៍ ការអប់រំភាគច្រើនត្រូវស្ថិតក្រោមការទទួលខុសត្រូវរបស់ក្រសួងនៅរដ្ឋាភិបាលណ្ដាល ហើយការងារផ្សេងទៀតត្រូវផ្ទេរទៅឲ្យរដ្ឋអំណាចមូលដ្ឋាន។ ការអប់រំត្រូវចាត់ទុកជាកាតព្វកិច្ចនៅប្រទេសមួយចំនួនអស់រយៈពេលជាយូរឆ្នាំមក ហើយ ប្រទេសខ្លះទៀតដើរតាមវិធីនេះដែរក្នុងពេលថ្មីៗនេះ។ ប្រទេសទាំងនោះវិភាគថា តើត្រូវអប់រំកុមាររួមគ្នា ឬអនុញ្ញាតឲ្យសាសនា និងសហគមន៍ទទួលភារកិច្ចអប់រំកុមារដាច់ ដោយឡែកពីគ្នា។ បញ្ហានេះប្រហែលជាកើតឡើងខុសៗគ្នានៅតាមប្រទេសផ្សេងគ្នា។

ដូច្នេះ ចាំបាច់ត្រូវវាយតម្លៃអំពីបទពិសោធន៍របស់ប្រទេសផ្សេងៗក្នុងក្របខ័ណ្ឌសកម្មភាពរួមមួយដើម្បីធានាបំពេញកាតព្វកិច្ចស្នូលដូចមានចែងនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងគោលដៅអប់រំសំរាប់ទាំងអស់គ្នា។ លទ្ធផលនៃការវាយតម្លៃនេះអាចបង្ហាញផ្លូវឲ្យយើងមើលឃើញការងារដែលត្រូវបំពេញបន្តសំរាប់តាក់តែង និងអនុវត្តគោលនយោបាយអប់រំផ្អែកលើសិទ្ធិមនុស្ស។ គោលនយោបាយនោះនឹងជួយបំពេញ

[4] Commission on Human Rights - Annual reports of the Special Rapporteur on the right to education, E/CN.4/1999/49, paras. 51-74; E/CN.4/2000/6, paras. 32-65, and E/CN.4/2001/52, paras. 64-65

ចន្លោះខ្វះខាត និងពង្រឹងយុទ្ធសាស្ត្រ និងគោលនយោបាយអប់រំដែលមានស្រាប់។ ការវាយតម្លៃនេះមិនត្រឹមតែជាសកម្មភាពដើម្បីវិស័យអប់រំតែមួយមុខទេ។

ដោយសារផែនការអប់រំសំរាប់ទាំងអស់គ្នារបស់ប្រទេសនីមួយៗយកចិត្តទុកដាក់លើការពង្រឹងសមត្ថភាពតាមស្ថាប័ន និងពង្រឹងគោលនយោបាយ របៀបវារៈសិទ្ធិមនុស្សត្រូវចាត់ទុកជាសកម្មភាពនិយាម ទោះជាវិស័យទាំងពីរនេះបំពេញចំណុចខ្វះខាតឲ្យគ្នាទៅវិញទៅមកក៏ដោយ។ សកម្មភាពនិយាមនេះគិតបញ្ចូលទាំងវិធានការរដ្ឋធម្មនុញ្ញ និងវិធានការច្បាប់ដែលសំដៅពង្រឹងការអនុវត្តសិទ្ធិទទួលការអប់រំ ដូចមានចែងនៅក្នុងច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

នៅប្រទេសមួយចំនួន វិធានការទាំងនេះមាននិយាយអំពីបញ្ញត្តិស្តីពីការបែងចែកថវិកាសំរាប់វិស័យអប់រំដែលត្រូវតែស្មើ ២៥ ភាគរយនៃថវិកាជាតិសរុប។ នៅប្រទេសខ្លះ វិសោធនកម្មរដ្ឋធម្មនុញ្ញ និងច្បាប់បានធានាផ្តល់សិទ្ធិទទួលការអប់រំតាមសាលារដ្ឋដោយឥតបង់ថ្លៃសំរាប់កុមារគ្រប់រូបដែលគ្រប់អាយុចូលរៀន វិធានការនេះក៏មានចែងបញ្ញត្តិស្តីពីការលុបបំបាត់ការរើសអើងផងដែរ។ ប្រទេសមួយចំនួនទៀតបានអនុវត្តការងារនេះជាច្រើនសកម្មភាពមកហើយ ដោយបង្កើតស្ថាប័នរដ្ឋដែលមានអំណាចក្នុងការ តាមដាន ត្រួតពិនិត្យការអនុវត្តសិទ្ធិមនុស្ស ផ្តល់អនុសាសន៍ និងពង្រឹងការអនុវត្តឲ្យកាន់តែមានប្រសិទ្ធភាព ហើយផ្តល់យោបល់កែប្រែច្បាប់ និងគោលនយោបាយបើចាំបាច់។ តាមវិធីនេះ តំណាងរបស់កុមារដែលមិនបានទទួលសិទ្ធិទទួលការអប់រំអាចមានលទ្ធភាពស្វែងរកជំនួយជាមួយគណៈកម្មការសិទ្ធិ មនុស្សនៅក្នុងប្រទេស ឬអង្គភាពវិនិច្ឆ័យយុត្តិធម៌សំរាប់កុមារ។